ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៨០

ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១

សាលដីកា

លេខ ២៨០ "VIII"

ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.ឯកឧត្តម [redacted] ជាចៅក្រម

៣.ឯកឧត្តម [redacted] ជាចៅក្រម

៤.ឯកឧត្តម [redacted] ជាចៅក្រម

៥.ឯកឧត្តម [redacted] ជាចៅក្រម

### ចៅក្រមរបាយការណ៍

ឯកឧត្តម [redacted]

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២៧០ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] លេង ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រVI "ប.ស" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] លេង ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ទីលំនៅមុនពេលឃុំខ្លួននៅ [redacted] ម្តាយឈ្មោះ [redacted]' នៅលើរ ជានិតិជន-ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

.ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៨១ តព្រ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ នៅពន្ធនាគារខេត្តព្រះវិហារ។

ជាប់ចោទពីបទ **រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោស) ដោយសារមូលហេតុអាយុជនរងគ្រោះ** ប្រ[redacted] ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុច១ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារសិទ្ធិលោក [redacted] ម្វ៉ា ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន[redacted] "រ" ម្ដាយឈ្មោះ [redacted]"ស" ប្ដីឈ្មោះ[redacted]"រ" មានកូន០៧នាក់ ។

-ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ ១៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន[redacted]"រ" ម្ដាយឈ្មោះ [redacted] "រ" នៅលីវ ។

មេធាវីការពារក្ដី និងតំណាងដោយអាណត្តិលោកស្រី [redacted]សូនី និងលោក[redacted]រ៉ាឌុច ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ០៩ យប់ ឈ្មោះ [redacted]លេង បានធ្វើសកម្មភាពចាប់រំលោភសេពសន្ថវៈលើក្មេងស្រីរងគ្រោះឈ្មោះ [redacted] ដោយពេលនោះម្ដាយឪពុករបស់ឈ្មោះ [redacted] មិននៅផ្ទះ គាត់បានចេញទៅចាប់កង្កែប ហើយឈ្មោះ[redacted]លេង គិតថាជាឱកាសល្អដោយមានតែពីរនាក់និងឈ្មោះ [redacted]ក្នុងពេលនោះឈ្មោះ [redacted] កំពុងបបរបាយជ្រូកនៅក្រោយផ្ទះ ពេលបបរបាយជ្រូករួចឈ្មោះ[redacted]ក៏បានឡើងទៅលើផ្ទះស្រាប់តែឈ្មោះ[redacted]លេង មកចាប់អោបនាងពីក្រោយរួចប្រឡេះឡេវខោនាង ស្រាតខោ និងផ្ដួលនាងទៅលើក្ដារ រួចឈ្មោះ[redacted]លេង បានយកដៃសង្កត់ទ្រូងនាង និងបានយកលិង្គមកដាក់បញ្ចូលក្នុងប្រដាប់ភេទរបស់នាង ប៉ុន្មាននាទីក្រោយមកឈ្មោះ [redacted]លេង បានក្រោកពីលើនាង ហើយដើរមកដេកវិញ។ លើកទី២ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១១ព្រឹក ពេលនោះនាងកំពុងតែដេកស្រាប់តែឈ្មោះ[redacted]លេង បានចូលក្នុងបន្ទប់របស់នាង ហើយចាប់សម្រាតខោក្នុង និងបានសើយសំពត់របស់នាងរំលោភបានសម្រេច។ លើកទី៣ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ១ថ្ងៃត្រង់ នាងកំពុងស្លៀកពាក់បម្រុងងូតទឹកស្រាប់តែឈ្មោះ[redacted]លេង បានចូលទៅអោប ហើយផ្ដួលនាងទៅនឹងកន្ទេលរួចធ្វើសកម្មភាពបានសម្រេច។ ក្រោយមកម្ដាយជនរងគ្រោះដឹងរឿង និងបានដាក់ពាក្យបណ្ដឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកតុលាការតែម្ដង ។



Scanned with CamScanner

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឃ" ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ[redacted]លេង ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៨ (ប្រាំបី)ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសដោយសារមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្ត[redacted]ត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុច១ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] លេង សងសំណងការខូចខាត និងជម្ងឺចិត្តទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]និងជនរងគ្រោះឈ្មោះ [redacted]ចំនួន ៤.០០០.០០០ (បួនលាន) រៀល ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ចំពោះមុខជនរងគ្រោះ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ២៣ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ[redacted]លេង ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឃ" ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រVI "ប.ស" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ២៣ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់ពិរុទ្ធជនឈ្មោះ[redacted]លេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឃ" ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លេង ចំពោះមុខឈ្មោះ [redacted] ប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២១។

-បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់

- **បានឃើញ** បណ្តឹងសាទុក្ខលេខ ២៧០ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] លេង ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រVI "ប.ស" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា៖ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ ហើយសេចក្តីសុំប្តឹងសាទុក្ខនៅសាលាឧទ្ធរណ៍ភ្នំពេញ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២១ ឃើញថា ហួសរយៈពេលកំណត់នៃច្បាប់ហើយ។ ម្យ៉ាងសាលដីកាសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានប្រកាសចំពោះមុខជនជាប់ចោទនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១។

ហេតុដូច្នេះ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។

+លោក [redacted] ឆូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនប្តឹងសាទុក្ខមកនេះព្រោះគាត់បានឆ្លើយនៅគ្រប់ដំណាក់កាលថា គាត់មិនបានប្រព្រឹត្តទេ។ មានមូលដ្ឋានដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌក្នុងការប្តឹងសាទុក្ខ។ សាលាឧទ្ធរណ៍សម្រេចពុំទាន់ត្រឹមត្រូវនៅឡើយទេ។ ការធ្វើកោសល្យវិច័យទៀតសោតធ្វើឡើង ៣ខែ ក្រោយពេលកើតហេតុ ពុំអាចសន្និដ្ឋានបានថានរណាជាអ្នកប្រព្រឹត្តនោះទេ គ្មានភស្តុតាងដើម្បីដាក់បន្ទុកលើជនជាប់ចោទ និងមានវិមតិសង្ស័យលើជនជាប់ចោទ។ តាមមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាគ្មានបទល្មើស មិនអាចដាក់ទោសលើជនជាប់ចោទបានទេ តុលាការកំពូលអាចសម្រេចលើកលែងចោទប្រកាន់លើជនជាប់ចោទបាន ។ ករណីដែលជនជាប់ចោទពុំបានប្រព្រឹត្តទេនោះ ទោសដាក់ពន្ធនាគាររយៈពេល៨ឆ្នាំគឺច្រើនណាស់។

សំណូមពរ សូមតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

+លោកស្រី [redacted] សូនី ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ការប្តឹងសាទុក្ខរបស់ជនជាប់ចោទធ្វើឡើងហួសរយៈពេលកំណត់ច្បាប់ហើយ ដែលមានចែងក្នុងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺការប្តឹងសាទុក្ខមានរយៈពេល១ខែ គិតពីថ្ងៃបានទទួលសាលដីការបស់សាលា



Scanned with CamScanner

ឧទ្ធរណ៍ គិតពីថ្ងៃប្រកាសសាលដីកាចំពោះមុខរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ តាំងពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ ទើបជនជាប់ចោទប្ដឹងសាទុក្ខ ដូចនេះ លើសរយៈពេលជាង៦ខែ។ ហេតុនេះ បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទពុំអាចឱ្យតុលាការពិចារណាបានទេ។ ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។

សំណូមពរ សូមតុលាការសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩០ ក្រVI "ប.ស" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ។

+លោក [redacted] ម៉ូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានបន្ថែមថា៖ ខ្លួនបានទាក់ទងទៅខាងពន្ធនាគារខេត្តព្រះវិហារ បានផ្ញើឯកសារមកឱ្យខ្លួនថា សាលដីការបស់សាលាឧទ្ធរណ៍បានបញ្ជូនទៅដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ជនជាប់ចោទប្ដឹងសាទុក្ខក្នុងអំឡុងពេល១ខែ។

+ជនជាប់ចោទឈ្មោះ [redacted] លេខ បានឆ្លើយថា៖ ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់លោកមេធាវីការពារសិទ្ធិឱ្យខ្លួន។ ខ្លួនមិនបានប្រព្រឹត្តទេ ហើយជាប់ក្នុងពន្ធនាគារដោយអយុត្តិធម៌បំផុត។

សំណូមពរ សូមតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

១.យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២៧០ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] លេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចសេចក្ដីតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឃ" ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការដដែល ដោយសំអាងហេតុថា តាមលទ្ធផលកោសល្យវិច័យ (ឯកសារការរំលោភផ្លូវភេទ) របស់មន្ទីរសុខាភិបាលខេត្តព្រះវិហារលេខ ០៩/១៧ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ និងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ដែលមានអាយុ១៧ឆ្នាំ គឺជាភស្តុតាងចម្បងសម្រាប់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] លេង ដែលមាន



Scanned with CamScanner

ចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈលើជនរងគ្រោះ នោះតុលាការកំពូលពិនិត្យឃើញថា ពុំមានមូលដ្ឋានច្បាស់លាស់នៅឡើយទេ ក្នុងការដាក់បន្ទុកលើជនជាប់ចោទថា ជនជាប់ចោទមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ដោយហេតុថា ផ្អែកតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] នៅក្នុងកំណត់ហេតុស្តាប់ការបំភ្លឺនៅថ្ងៃទី១៦-១៧ ខែមេសា ឆ្នាំ២០១៧ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ តុលាការកំពូលពិនិត្យឃើញថា ជនរងគ្រោះពុំឃើញមានការឆ្លើយបញ្ជាក់ថា សកម្មភាពរំលោភសេពសន្ថវៈរបស់ជនជាប់ចោទ មកលើជនរងគ្រោះលើកទី១ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ លើកទី២នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ និងលើកទី៣នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ មានការប្រើប្រាស់អំពើហិង្សា ឬមួយមានការគំរាមកំហែងអ្វីមកលើជនរងគ្រោះនោះទេ ហើយជនរងគ្រោះដែលត្រូវបានជនជាប់ចោទរំលោភនោះ ក៏គ្មានការរើបំរាស់ប្រឆាំងតបតនឹងអំពើរបស់ជនជាប់ចោទ ដែលបានរំលោភមកលើរូបខ្លួនចំនួន បីដងនោះដែរ។ លើសពីនេះទៅទៀតនៅពេលជនជាប់ចោទបានរំលោភលើជនរងគ្រោះលើកទី១រួចហើយ ជនរងគ្រោះបានជួបនឹងបងរបស់ខ្លួន ប៉ុន្តែជនរងគ្រោះមិនបានប្រាប់បងខ្លួនថា ជនជាប់ចោទបានរំលោភលើរូបខ្លួនទេ។

៣.យល់ឃើញថា ឆ្លងតាមលទ្ធផលនៃការសួរដេញដោលនាពេលសវនាការ និងការពិនិត្យមើលឯកសារនៅក្នុងសំណុំរឿង និងចម្លើយរបស់ជនរងគ្រោះនៅក្នុងកំណត់ហេតុស្តាប់ការបំភ្លឺរបស់ជនរងគ្រោះឈ្មោះ [redacted] នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] លេង ថា មានចេតនាទុច្ចរិតក្នុងការប្រព្រឹត្ត បទរំលោភសេពសន្ថវៈ (ស្ពានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) តាមបញ្ញត្តិមាត្រា ២៤១ ចំណុច១ នៃក្រមព្រហ្មទណ្ឌទេ។ ដូច្នេះ អនុលោមតាមបញ្ញត្តិមាត្រា ៣៥០ វាក្យខណ្ឌទី៣ និងមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការកំពូលសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] លេង រួចផុតពីបទចោទប្រកាន់។

៤.យល់ឃើញថា នាពេលសវនាការមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះសុំឱ្យតុលាការកំពូលតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រVI “ប.ស” ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែលដោយសំអាងថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទលើសកំណត់ច្បាប់ជាង ០៦ខែហើយ នោះតុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះថា សាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រVI “ប.ស” ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ បានប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដោយការប្រកាសនេះជនជាប់ចោទអវត្តមាន រហូតដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ទើបជនជាប់ចោទបានទទួលនូវសេចក្តីសម្រេចនៃសាលដីការបស់សាលាឧទ្ធរណ៍ ខាងលើនេះ ហើយនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ជនជាប់ចោទបានប្តឹងសាទុក្ខ។ ដូច្នេះ យោងតាមមាត្រា ៤២០ និងមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ពុំលើសកំណត់នៃច្បាប់ទេ។



Scanned with CamScanner

៥.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រVI “ប.ស” ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចមកនេះ ខុសនឹងគតិច្បាប់។

## ហេតុដូច្នេះ

## ទិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ ២៧០ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]លេង ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៤០ ក្រVI “ប.ស” ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញទាំងមូល ។

៣-ឲ្យឈ្មោះ [redacted] លេង រួចខ្លួនពីបទចោទ រំលោភសេពសន្ថវៈ (ស្ពានទម្ងន់ទោស) ដោយសារមូលហេតុអាយុជនរងគ្រោះ ប្រព្រឹត្ត[redacted]ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២៤១ ចំណុច១ នៃក្រមព្រហ្មទណ្ឌ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសនាពេលសវនាការជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។

ថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner